**ព្រះរាជាណាចក្រ កម្ពុជា**

*Kingdom Of Cambodia*

**ជាតិ សាសនា ព្រះមហាក្សត្រ**

Nation Religion King

**គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់**

Land Appraisal and Valuation Committee

លេខ.០០៥...សសរ.សហវ.ពដ

លិខិតចូល
ថ្ងៃទី២០....ខែមិថុនា ឆ្នាំ2006

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០០៦

## សេចក្តីសំរេច

### ស្តីពី

### ការកែប្រែសមាសភាពអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ខេត្តកំពង់ធំ

### ប្រធានគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧០៤.១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកម-០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១-នស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤
- បានឃើញច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០២៩៧-០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៥៨-អនក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ២២៤ ប្រក-សហវ-ពដ ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់

- បានឃើញសេចក្តីសំរេចលេខ ០០៩-សសរ-សហវ-៣ដ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បានឃើញប្រកាសលេខ ៣៩៣ ប្រក-សហវ-៣ដ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ១៩៩៩ ស្តីពីការកែប្រែសមាសភាពគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសេចក្តីសំរេចលេខ ០០១ សហវ.៣ដ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់
- បានឃើញសំណើរបស់ប្រធានអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅខេត្តកំពង់ធំលេខ ១១៦ ស.ណ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៥ ស្តីពីសំណើសុំប្តូរឈ្មោះសមាជិកអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ខេត្តកំពង់ធំ ចំនួន២រូប និងប្តូរមុខដំណែងថ្មី ចំនួន១រូប
- យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅខេត្តកំពង់ធំ ។

## សំរេច :

**ប្រការ១:** សមាសភាពនៃអនុគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅខេត្តកំពង់ធំ ដែលមាននៅក្នុងសេចក្តីសំរេចលេខ ០០១ សហវ.៣ដ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ត្រូវបានកែប្រែដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ណាំ ទុំ | អភិបាលខេត្ត | ជាប្រធាន |
| ២- លោក ជា ៣ | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | ជាអនុប្រធាន |
| ៣- លោក ឱប ចាន់ | ប្រធានសាខាពន្ធដារខេត្ត | ជាអនុប្រធាន |
| ៤- លោក សុខ លូ | នាយខុទ្ទកាល័យសាលាខេត្ត | ជាសមាជិក |
| ៥- លោក អ៊ូ បុស្សរ័ត្ន | ប្រធានស្តីទីមន្ទីរកសិកម្មខេត្ត | ជាសមាជិក |
| ៦- លោក ឌិត ធន | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | ជាសមាជិក |
| ៧-លោកស្រី ស្រី សារីន | នាយិកាក្រុមហិរញ្ញវត្ថុសាលាខេត្ត | ជាសមាជិក |

**ប្រការ២:** អនុគណៈកម្មការមានភារៈកិច្ច :

- ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់
- បង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត-ក្រុង
- លើកគំរោងតម្លៃដីក្នុងមួយម៉ែត្រក្រឡា គិតតាមតំបន់និមួយៗក្នុងខេត្ត-ក្រុង ដើម្បីជាមូលដ្ឋានគណនាប្រាក់ពន្ធដាក់ជូនគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ពិនិត្យនិងសំរេច
- ផ្តល់មតិចំពោះរឿងវិវាទនានា ដែលពាក់ព័ន្ធទៅនឹងដីមិនប្រើប្រាស់ ។

**ប្រការ៣:** អនុគណៈកម្មការអាចរៀបចំបង្កើតក្រុមជំនួយការមួយ ដើម្បីធានានិរន្តរភាពក្នុងប្រតិបត្តិការរបស់អនុគណៈកម្មការ ។

**ប្រការ៤:** សមាជិកអនុគណៈកម្មការ ត្រូវចូលរួមធ្វើការងារនិងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានអនុគណៈកម្មការ ។

**ប្រការ៥:** អនុគណៈកម្មការត្រូវចូលរួមធ្វើការងារនិងប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធានគណៈកម្មការនិងត្រូវរាយការណ៍ជាប្រចាំតាមខែនិមួយៗ មកគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ៦:** ឯកឧត្តម អស់លោក-លោកស្រី ដូចមានរាយនាមក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារៈកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រធានគណៈកម្មការដោះស្រាយដីធ្លីមិនបានប្រើប្រាស់ ៗ**

ចង់ វិបុល

**រដ្ឋលេខាធិការទី១ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងស្ថាប័នកណ្តាល
-គ្រប់សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាបជាពត៌មាន"
-ដូចប្រការ៦ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ